# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អធិប្បាយអំពីការធ្វើសង្គាយនាចំនួន៥លើករបស់ព្រះអរហន្តជាសាវ័កដើម្បីរៀបចំធម៌វិន័យមិនឲ្យបាត់បង់ បន្ទាប់ពីព្រះពុទ្ធបរិនិព្វានទៅ

web site: hoksavann.org

ថ្ងៃទី១៧ មីនា ២០០៥

ពាក្យថា <សង្គាយនា> ប្រែថាការរួបរួមធម៌វិន័យទុកជាពួកជាក្រុម ដើម្បីឲ្យស្រណុកក្នុងការសិក្សារៀនសូត្រ ។ បន្ទាប់ពីព្រះពុទ្ធបរិនិព្វានទៅ ដោយខ្លាចធម៌វិន័យរបស់ព្រះអង្គបាត់បង់ ព្រះសង្ឃដែលជាព្រះអរហន្តបានរួមប្រជុំគ្នាជាមហាសន្និបាតចំនួន៥លើក ក្នុងសម័យកាលផ្សេងៗគ្នា ដើម្បីផ្ទៀងផ្ទាត់ធម៌វិន័យឲ្យបានត្រឹមត្រូវ តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ហៅថាការធ្វើសង្គាយនា ដែលមានព្រឹត្តិការណ៍តាមដំណើរសង្គាយនានីមួយៗដូចតទៅនេះ ៖

១- បឋមសង្គាយនា = សង្គាយនាលើកទី១ ធ្វើក្នុងពេលដែលព្រះពុទ្ធបរិនិព្វានទៅបាន៣ខែ ដើម្បីរក្សាការពារធម៌វិន័យរបស់ព្រះពុទ្ធ ដោយលើកយកបញ្ហាភិក្ខុមួយអង្គនាម សុភទ្ទៈបានពោលតិះដៀលធម៌វិន័យ ។ ព្រះសង្ឃដែលមកប្រជុំមានចំនួន៥០០អង្គ ដែលមានព្រះមហាកស្សបៈជាអ្នកសួរ ព្រះឧបាលីជាអ្នកឆ្លើយព្រះវិន័យ, ព្រះអានន្ទជាអ្នកឆ្លើយព្រះសូត្រនិងព្រះអភិធម្ម ។ ព្រះអរហន្តទាំងបីអង្គសួរឆ្លើយត្រូវគ្នាហើយ ទើបសួរបញ្ជាក់ទៅព្រះអរហន្តបដិសម្ភិទាញ្ញាណ ជាសមាជិកអង្គប្រជុំទាំង៥០០អង្គ ឆ្លើយត្រូវគ្នាទៀត ទើបទុកជាបានការ ។ សង្គាយនានេះធ្វើនៅក្រុងព្រះរាជគ្រឹះ មានព្រះបាទអជាតសត្រូវជាសាសនូបត្ថម្ភក៍ ធ្វើអស់រយៈវេលា៧ខែទើបចប់ ។ ព្រះនាមព្រះមហាថេរទាំងបីព្រះអង្គ ដែលសួរឆ្លើយក្នុងសង្គាយនាលើកទី១នេះហើយ ដែលអ្នកទេសនាត្រៃបីសម័យក្រោយមករហូតដល់សព្វថ្ងៃនេះ យកមកប្រើដាក់នាមរបស់ខ្លួនក្នុងទេសនាត្រៃបី ។

២- ទុតិយសង្គាយនា = សង្គាយនាលើកទី២ ធ្វើក្នុងពេលព្រះពុទ្ធបរិនិព្វានទៅបាន១០០ឆ្នាំ ដោយប្រារព្ធចំពោះពួកភិក្ខុវជ្ជីបុត្រ ដោយបញ្ញត្តិប្រកាន់វត្ថុ១០ប្រការខុសធម៌វិន័យ ។ មានព្រអសង្ឃជាព្រអអរហន្តបដិសម្ភិទាញ្ញាណ ជាសមាជិកអង្គប្រជុំចំនួន៧០០អង្គ ។ ព្រះរេវតៈជាអ្នកចោទសួរវត្ថុ១០ប្រការ ព្រះសព្វកាមិជាអ្នកឆ្លើយ ធ្វើនៅនគរវេសាលី ព្រះបាទកាលាសោកជាសាសនូបត្ថម្ភក៍ ធ្វើអស់រយៈពេល៨ខែទើបចប់។

៣- តតិយសង្គាយនា = សង្គាយនាលើកទី៣ ធ្វើក្នុងពេលព្រះពុទ្ធបរិនិព្វានទៅបាន២១៨ឆ្នាំ ។ ព្រះបាទធម្មាសោកបានសោយរាជសម្បត្តិក្នុងសកលជម្ពូទ្វីប គឺប្រទេសឥណ្ឌា ក្រុងបាដលីបុត្រ ទ្រង់មានព្រះទ័យជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បានញ៉ាំងលាភសក្ការៈជាច្រើនដល់ព្រះសង្ឃពេលនោះ ពួកនិគ្រន្ថដែលមានការក្រលំបាកប្រាថ្នាលាភសក្ការៈ ក៏លបចូលបួសបន្លំជាច្រើន ហើយយកលទ្ធិរបស់ឲ្យខ្លួនមកសំដែងថា ជាពុទ្ធសាសនា ដែលធ្វើឲ្យព្រះពុទ្ធសាសនាមានមន្ទិលសៅហ្មង ។ គ្រានោះព្រះសង្ឃបែកគ្នាខានធ្វើឧបោសថអស់៧ឆ្នាំ ទើបព្រះបាទធម្មាសោកជំរះមន្ទិលទាំងនោះដោយប្រើអាមាត្យឲ្យចាប់ពួកនិគ្រន្ថផ្សឹកទាំងអស់ ទុកតែព្រះសង្ឃដែលបរិសុទ្ធ ។ បន្ទាប់មកផ្តើមធ្វើសង្គាយនាលើកទី៣ ដោយព្រះមោគ្គលីបុត្តតិស្សត្ថេរជាប្រធាន មានព្រះអរហន្ត១,០០០អង្គ ធ្វើក្នុងអសោការាម ក្រុងបាដលីបុត្ត មានព្រះបាទធម្មាសោកជាសាសនូបត្ថម្ភក៍ ធ្វើអស់រយៈវេលា៩ខែទើបចប់ ។

៤- ចតុត្ថសង្គាយនា = សង្គាយនាលើកទី៤ ធ្វើក្នុងពេលព្រះពុទ្ធបរិនិព្វានទៅបាន២៣៦ឆ្នាំ បំណងដើម្បីឲ្យពុទ្ធសាសនាតាំងនៅស៊ប់សួនក្នុងលង្កាទ្វីប ដោយព្រះមោគ្គលីបុត្តតិស្សត្ថេរបានចាត់ឲ្យព្រះអរហន្តផ្សាយព្រះពុទ្ធសាសនាទៅប្រទេសផ្សេងៗក្នុងបច្ចន្តប្រទេស ជាពិសេសបានចាត់ព្រះមហិន្ទត្ថេរឲ្យផ្សាយពុទ្ធសាសនានៅលង្កាទ្វីប រហូតដល់ព្រះបាទទេវានម្បិយតិស្សៈនៃនគរនេះមានសទ្ធាជ្រះថ្លា សុំព្រះមិត្តាថេរីជាព្រះរាជធីតានៃព្រះបាទធម្មាសោកទីក្រុងបាដលីបុត្តជម្ពូទ្វីបមកបំបួសព្រះនាងអនុឡាជាព្រះអនុជទៀតផង ។ បន្ទាប់មកដើម្បីពុទ្ធសាសនាចាក់ឫសនៅលង្កាទ្វីប ក៏ចាប់ផ្តើមធ្វើសង្គាយនាដោយព្រះមហិន្ទត្ថេរជាអ្នកបុច្ឆា ព្រះអរិដ្ឋត្ថេរជាអ្នកវិសជ្ជនា មានព្រះសង្ឃ៦៨,០០០អង្គ ធ្វើនៅថូបារាមក្នុងអនុរាធបុរី ព្រះបាទទេវានម្បិយតិស្សៈជា សាសនូបត្ថម្ភក៍ ធ្វើអស់វេលា១០ខែទើបចប់ ។

៥- បញ្ចមសង្គាយនា = សង្គាយនាលើកទី៥ ប្រារព្ធចំពោះព្រះសង្ឃដែលបែកគ្នាជាពីរពួក គឺព្រះសង្ឃខាងមហាវិហារនិងព្រះសង្ឃខាងអភយគីរីវិហារ ធ្វើនៅមហាវិហារនៃលង្កាទ្វីប មានព្រះសង្ឃ១,០០០អង្គ មានព្រះពុទ្ធទត្តត្ថេរជាអ្នកសួរ ព្រះតិស្សត្ថេរជាអ្នកឆ្លើយ ព្រះបាទវដ្តគាមិនីអភ័យ ក្សត្រក្រុងលង្កាទ្វីបជាសាសនូបត្ថម្ភក៍ ធ្វើអស់រយៈវេលា១២ខែទើបចប់ ។ បន្ទាប់មកទើបចារឹកព្រះត្រៃបិដកជាតួរអក្សរដាក់ក្នុងស្លឹករឹត ។ ដូច្នេះពុទ្ធវចនៈពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធបានសរសេរជាលាយលក្ខណ៍អក្សរ នៅក្នុងសង្គាយនាលើកទី៥នេះឯង ដែលកាលពីមុនព្រះសង្ឃជាព្រះអរហន្តចេះចាំពុទ្ធវចនៈនៅក្នុងចិត្ត ។

តមកអស់កាលជាច្រើនសតវត្សរ៍ គ្មានឃើញសង្គាយនាដើម្បីប្រារព្ធរឿងហេតុអ្វីឡើយ ។ ទើបតែមកដល់សតវត្សរ៍ទី២០នៃគ.ស. ទើបមានធ្វើឆដ្ឋសង្គាយនា គឺសង្គាយនាលើកទី៦ នៅទីក្រុងរង្គូន ប្រទេសភូមា ដែលមានសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកជួន-ណាត និមន្តទៅជាតំណាងប្រទេសកម្ពុជានៅពេលនោះ ។ ក្រៅពីនោះ នៅថ្ងៃ២៦ ឧសភាដល់៤មិថុនា១៩៥០ មានធ្វើសមាជសកលពុទ្ធសាសនានៅទីក្រុងកូឡុំបូប្រទេសសេរីលង្កា ដែលមានប្រទេសជាង៤០បានចូលរួម ។ បន្ទាប់មកនៅថ្ងៃ២៥កញ្ញាដល់១៣តុលា១៩៥២ មានធ្វើសមាជសាកលពុទ្ធសាសនាម្តងទៀតនៅទីក្រុងតូក្យូប្រទេសជប៉ុន ដែលមានប្រទេសចំនួន៥០ចូលរួមប្រជុំ ។ ការប្រជុំព្រះពុទ្ធសាសនាទាំងពីរលើកនេះ ដើម្បីរកសន្តិភាពជូនសកលលោក ។៚